អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងប្រកាសអំពីកាលបរិច្ឆេទសម្រាប់បើកសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២

នៅថ្ងៃនេះអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា សេចក្តីថ្លែងបើកនៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២ នឹងចាប់ផ្តើមនៅម៉ោង ៩:០០ ព្រឹក ថ្ងៃច័ន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ នៅបន្ទប់សវនាការនៅ អ.វ.ត.ក និងបន្តទៅថ្ងៃបន្តបន្ទាប់ទៀត។ ការស្តាប់ភស្តុតាងនៅក្នុងសំណុំរឿងនេះនឹងចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១។ សវនាការបឋមនៅក្នុងសំណុំរឿង ០០២ ដែលចាត់ទុកថាជាការបើកការជំនុំជម្រះផ្លូវការ អនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក បានដំណើរការនៅចំពោះមុខអង្គជំនុំជម្រះពីថ្ងៃទី២៧ ដល់ទី៣០ ខែមិថុនា ឆ្នាំ២០១១។

សវនាការនៅថ្ងៃច័ន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ នឹងចាប់ផ្តើមដោយការអានបទចោទមកលើជនជាប់ចោទ។ បន្ទាប់មក សហព្រះរាជអាជ្ញានឹងទទួលបានរយៈពេលពីរថ្ងៃក្នុងការធ្វើសេចក្តីថ្លែងបើករបស់ខ្លួន។ ទោះបីនាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ជាវគ្គតូចៗក្តី តែការជំនុំជម្រះនៅវគ្គទីមួយនឹងផ្តល់ជាមូលដ្ឋានទូទៅ សម្រាប់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទ រួមទាំងបុគ្គលនានាដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះក្រោយៗទៀត។ ហេតុនេះ សហព្រះរាជអាជ្ញានឹងធ្វើសេចក្តីថ្លែងបើក ពាក់ព័ន្ធនឹងបទចោទ និងអង្គហេតុចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២។ បន្ទាប់មក មេធាវីការពារក្តីជនជាប់ចោទនីមួយៗនឹងមានឱកាសក្នុងការឆ្លើយតបទៅនឹងសេចក្តីថ្លែងបើករបស់សហព្រះរាជអាជ្ញា។ ក្រុមមេធាវីការពារក្តីនីមួយៗនឹងទទួលបានរយៈពេលមួយថ្ងៃកន្លះសម្រាប់ធ្វើសេចក្តីថ្លែងបើករបស់ខ្លួន។

បន្ទាប់ពីចប់សេចក្តីថ្លែងបើក ការស្តាប់ភស្តុតាងក្នុងសំណុំរឿង ០០២ នឹងចាប់ផ្តើមនៅម៉ោង ៩:០០ ព្រឹក ថ្ងៃច័ន្ទ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១។ វគ្គដំបូងនៃការជំនុំជម្រះនឹងបញ្ចប់ត្រឹមថ្ងៃសុក្រ ទី១៦ ខែធ្នូ ឆ្នាំ



Original EN: 01699218-01699218

២០១១ ហើយនៅពេលនោះ អង្គជំនុំជម្រះនឹងផ្អាកសវនាការដោយសារបុណ្យណូអែល និងបុណ្យចូលឆ្នាំថ្មី។ បន្ទាប់ពីការឈប់សម្រាកនេះ កិច្ចដំណើរការនីតិវិធីជំនុំជម្រះនឹងបន្តធ្វើនៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃច័ន្ទ ទី០៩ ខែមករា ឆ្នាំ២០១២។ កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើជាសាធារណៈ ឲ្យបានជាអតិបរមា តាមដែលអាចធ្វើបាន។

អង្គជំនុំជម្រះសាលាដំបូងនឹងជូនព័ត៌មានបន្ថែមទៀត ពាក់ព័ន្ធនឹងការកំណត់ពេលវេលាសម្រាប់ការជំនុំជម្រះវគ្គក្រោយៗទៀត ទៅតាមពេលវេលាសមស្រប។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការចាប់ផ្តើមការជំនុំជម្រះលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ សូមទាក់ទង៖

**លោក Lars OLSEN**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទ៖ +៨៥៥(0)-១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុ៖ +៨៥៥ ២៣ ២១៩ ៨១៤ លេខបន្ត ៦១៦៩
អ៊ីមែល៖ olsen@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីអ្នកនាំពាក្យ
ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៣ ២៨៣
អ៊ីមែល៖ neth.phektra@eccc.gov.kh